# ឆ្នាំ ២០១៩

## ឆ្នាំ ២០១៩

ពេលវេលាដែលចេះតែកន្លងទៅមុខ, តែឆ្នាំថ្មីក៏ដូចជាឆ្នាំចាស់ ប៉ុន្តែ ជាតិសាសន៍ខ្មែរ កំពុងរំកិលបន្ទិចម្តងៗ ទៅរកប៉ាន នៅក្នុងសន្ទិភាព នៃពេជ្ឈឃាត។ ដូច្នោះ កត្តា នៃពេលវេលា វាជាសត្រូវនឹងខ្មែរ ហើយ កម្រាស់ពេល មាននៅក្នុងប្រវត្តិសាស្ត្រជាតិ ក៏បង្ហាញដែរថាវាដូច្នោះឯង។ ចំពោះខ្មែរគំនិតថា « ថ្ងៃស្អែក វានឹងគ្រាន់បើជាងសព្វថ្ងៃ » វាគ្រាន់តែជា ការរង់ចាំអកម្ម នៅក្នុងសេចក្តីអស់សង្ឃឹមតែប៉ុណ្ណោះ។ ហើយគំនិតថា « ពីដើម វាគ្រាន់បើជាងសព្វថ្ងៃ » វាគ្រាន់តែជា ចំណាប់អារម្មណ៍ ពោរពេញទៅដោយបដិយចិត្ត នៅក្នុងតួនាទី ជាអ្នកឈរមើលអកម្ម នូវការវិវត្តន៍ នៃព្រឹត្តិការណ៍ជាតិ។ មែនទែនគំនិតទាំងពីរនេះ វាមានសារជាតិតែមួយដូចគ្នាគឺ ការលះបង់សិទ្ធខ្លួនជាម្ចាស់វាសនា ឱ្យទៅអ្នកដទៃ នឹងបន្ត ការអត់ធ្មត់ទ្រាំទ្រ នៅក្នុងអនាគតគ្មានត្រើយ។ បន្ថែម នូវការខ្វះ នៃការផ្តួតផ្ដើមគំនិត របស់ពលរដ្ឋខ្មែរម្នាក់ៗ វានាំឱ្យប្រជាជាតិ គ្មានទស្សនវិស័យរួម ដែលវាជា ចលករ នៃកម្លាំងប្រជាពលរដ្ឋ សំរាប់កសាងអនាគតប្រជាជាតិ។ ខ្មែរ និង ខ្មែរលែងមានសេចក្តីទុកចិត្ត រវាងគ្នានិងគ្នា ព្រោះប្រជាពលរដ្ឋ បាត់ នូវស្នាមចំណាំថាអ្វីខ្លះ ដែលជាគ្រឹះរួម នៃប្រជាជាតិខ្លួន ដែលវាអាច

## ឆ្នាំ ២០១៩

ឱ្យយួន គេសន្ធត់ឱ្យខ្មែរ ទុកថ្ងៃទី៧មករា ជាថ្ងៃសង្គ្រោះជាតិ និង ដំណើរថ្មី នៃកម្ពុជា នៅក្រោមការត្រួតត្រា របស់យួន។ ដូច្នោះ ឆ្នាំ ២០១៩ វាគ្រាន់តែជាឆ្នាំ របស់ប្រជាពលរដ្ឋខ្មែរ បន្ត លះបង់សិទ្ធខ្លួនជាម្ចាស់ស្រុកឱ្យទៅយួន នឹងបន្តអត់ធ្មត់ទ្រាំទ្ររស់នៅក្នុងអំណាចផ្តាច់ការ ដែលយួនគេជាអ្នកបង្កើត និង តុបតែង សំរាប់បំរើប្រយោជន៍គេ។ យួន គេធ្វើបាន ព្រោះខ្មែរ ស្ពឹក នៅចំពោះមុខ ទង្វើទាំងឡាយ របស់យួនមកលើប្រជាជាតិខ្លួន ទោះបីដឹងច្បាស់ថា វាជាមហិច្ឆិតាពាន់ឆ្នាំ របស់យួន គឺ ហួតចូលស្រុកខ្មែរ ទៅក្នុងស្រុកយួន ដែលគេធ្លាប់ធ្វើបានប្រកប ដោយ ជោគជ័យរួចមកហើយ គឺលេបទឹកដីកម្ពុជាក្រោម។ របបដឹកនាំសព្វថ្ងៃ ធ្វើស្ពូប ហៅឈ្មោះ « ឈ្នះឈ្នះ » សំរាប់ឃុំព្រលឹងជាតិខ្មែរ ទុកជាកតវេទិតា ដល់កងទ័ពយួន នៅចំពោះមុខខ្មែរទាំងនគរ ដែលពួកអ្នកដឹកនាំ គេសន្ធត់ថា ជាប្រជាជន ដែលត្រូវតែនឹកតបស្នងគុណដល់យួន ជាអ្នកមានគុណអស់មួយជីវិត។ ឈ្នះឈ្នះ នោះ គឺជា វិជ្ជ: របស់យួន ហើយ វា ពុំមែនជាគ្រោះថ្នាក់ របស់ប្រជាជាតិខ្មែរនោះឡើយ គឺវាជាការស្ម័គ្រចិត្ត របស់ពួកអ្នកដឹកនាំខ្មែរសព្វថ្ងៃ បំរើយួនតែម្តង។ ដូច្នេះ អ្វីដែលខ្មែរ រង់ចាំនៅឆ្នាំ ២០១៩ វាគ្មានអ្វីក្រៅពី នាំគ្នាឈប់រាប់ចំនួនជនជាតិយួន បន្តហូរចូលក្នុងស្រុកខ្មែរ ដូចរលកយក្ស ជោកជោះ រឫជម៌និងបំផ្លាញប្រយោជន៍ ជាតិខ្មែរ។ បើខ្មែរនៅតែ សំងំចាំខ្យល់ នៃសេចក្ដីសង្ឃឹមពីមស្ចឹមប្រទេស គឺពិតជានាំគ្នារង់ចាំសេចក្ដីស្លាប់នោះឯង៖